ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

គណៈកម្មាធិការប្រឡងថ្នាក់ជាតិ

លេខ: ៨៩/២៨ គ.ប.ជ

រាជធានីភ្នំពេញថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥

## សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងចេញថ្នាក់ជាតិ នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល សម័យប្រឡងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥

គណៈកម្មាធិការប្រឡងថ្នាក់ជាតិ សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល សូមជម្រាបដល់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល និងនិស្សិតទាំងអស់ឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០១៥នេះ គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងធ្វើការប្រឡងចេញថ្នាក់ជាតិ មានផ្នែកទ្រឹស្តី និងផ្នែកជំនាញគ្លីនិក ចំពោះនិស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិ នាសម័យប្រឡងថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០១៥ ព្រមទាំងឆ្នាំកន្លងមក និងចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមិនទាន់បានប្រឡងចេញថ្នាក់ជាតិ សម្រាប់ថ្នាក់វេជ្ជបណ្ឌិតទូទៅ បរិញ្ញាបត្រឱសថ ទន្តបណ្ឌិតទូទៅ និងបរិញ្ញាបត្រគិលានុបដ្ឋាក តាមលក្ខខណ្ឌ និងបែបបទប្រឡងដូចខាងក្រោម៖

### ១-លក្ខខណ្ឌនៃការប្រឡង

១.១.ចំពោះនិស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិមុនឆ្នាំ២០១៥៖

- បេក្ខជនត្រូវមានឈ្មោះនៅក្នុងបញ្ជីប្រឡងចេញថ្នាក់ជាតិមុនឆ្នាំ២០១៥
- បេក្ខជនដែលប្រឡងធ្លាក់ផ្នែកទ្រឹស្តី ត្រូវដាក់ពាក្យសុំប្រឡងតែផ្នែកទ្រឹស្តីឡើងវិញ
- បេក្ខជនដែលប្រឡងធ្លាក់ផ្នែកជំនាញគ្លីនិក ត្រូវដាក់ពាក្យសុំប្រឡងឡើងវិញ តែស្ថានីយ៍ណាដែលធ្លាក់

១.២.ចំពោះនិស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិក្នុងឆ្នាំ២០១៥៖

- បេក្ខជនត្រូវមានឈ្មោះនៅក្នុងបញ្ជីប្រឡងចេញថ្នាក់ជាតិក្នុងឆ្នាំ២០១៥
- បេក្ខជនដែលប្រឡងធ្លាក់ផ្នែកទ្រឹស្តី ត្រូវដាក់ពាក្យសុំប្រឡងទាំងផ្នែកទ្រឹស្តី និងទាំងផ្នែកជំនាញគ្លីនិកឡើងវិញ
- បេក្ខជនដែលប្រឡងធ្លាក់ផ្នែកជំនាញគ្លីនិក ត្រូវដាក់ពាក្យសុំប្រឡងឡើងវិញ តែស្ថានីយ៍ណាដែលធ្លាក់

១.៣.ចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមិនទាន់បានប្រឡងចេញថ្នាក់ជាតិ បេក្ខជនត្រូវមានៈ

- ◦ វិញ្ញាបនបត្របញ្ចប់ការសិក្សាចេញដោយគ្រឹះស្ថានបណ្តុះបណ្តាលដែលមានអាជ្ញាប័ណ្ណ
- ◦ ព្រឹត្តបត្រពិន្ទុនៃការសិក្សាគ្រប់មុខវិជ្ជា និងគ្រប់ឆ្នាំសិក្សា ចេញដោយគ្រឹះស្ថានបណ្តុះបណ្តាល
- ◦ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចេញដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា ឬ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ខេត្ត ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ឬ គណៈកម្មាធិការវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា
- ◦ ឈ្មោះក្នុងលទ្ធផលប្រឡងជាប់ចូលរៀនថ្នាក់ជាតិក្នុងវិស័យសុខាភិបាល ឬ លទ្ធផលប្រឡង ឬ ជ្រើសរើសជាប់ចូលរៀន ដែលមានហត្ថលេខាទទួលស្គាល់ដោយក្រសួងសុខាភិបាល និង/ឬ ក្រសួងអប់រំ យុវជន និងកីឡា

<u>បញ្ជាក់</u>៖

១. និស្សិតដែលបានបញ្ចប់ការធ្វើសារណាឬនិក្ខេបបទ ឬ មិនទាន់បានបញ្ចប់ ត្រូវបានអនុញ្ញាតឱ្យជំពាក់ដើម្បីបានដាក់ពាក្យសុំចូលរួមការប្រឡងចេញថ្នាក់ជាតិទាំងផ្នែកទ្រឹស្តី និងទាំងជំនាញគ្លីនីក។

២. គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងរៀបចំការប្រឡងចេញថ្នាក់ជាតិចំនួនពីរ(០២)ដង ក្នុងមួយឆ្នាំ

៣. និស្សិតត្រូវប្រឡងជាប់ការប្រឡងផ្នែកទ្រឹស្តីជាមុន ទើបអនុញ្ញាតឱ្យចូលរួមការប្រឡងជំនាញគ្លីនីក សម្រាប់សម័យប្រឡងថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៥

៤. និស្សិតមានសិទ្ធិប្រឡងចេញថ្នាក់ជាតិ សរុបចំនួនបួន(០៤)ដង មិនឱ្យលើសរយៈពេលបី(០៣)ឆ្នាំ

៥. និស្សិតដែលប្រឡងធ្លាក់ផ្នែកទ្រឹស្តី ក៏ដូចផ្នែកជំនាញគ្លីនីក នៅក្នុងការប្រឡងចេញថ្នាក់ជាតិ ចាប់ពីឆ្នាំ២០១៦តទៅ ត្រូវប្រឡងឡើងវិញទាំងផ្នែកទ្រឹស្តី និងទាំងផ្នែកជំនាញគ្លីនីក គ្រប់ស្ថានីយ៍ទាំងអស់ឡើងវិញ ទោះបីជាធ្លាក់តែស្ថានីយ៍ណាមួយក៏ដោយ។

## ២.វិញ្ញាសា កាលបរិច្ឆេទ និងទីកន្លែងប្រឡង

២.១. ផ្នែកទ្រឹស្តី

វិញ្ញាសាសំណេរ ជាប្រភេទសំណួរ Multiple Choices Question - MCQ មានចំនួន២០០សំណួរ ដែលការប្រឡងសំណេរនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥តាមមុខវិជ្ជា និងកាលបរិច្ឆេទដូចខាងក្រោម៖

❖ **ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥ ចាប់ពីម៉ោង ១៣:៣០នាទីតទៅ**

ក. ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖

- មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ — ២០ សំណួរMCQ
- ជម្ងឺទូទៅ — ៤០ សំណួរMCQ
- ជម្ងឺវះកាត់ — ៤០ សំណួរMCQ

ខ.ថ្នាក់បរិញ្ញាបត្រឱសថ៖

- មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រឥរិយាបថ — ៤០ សំណួរMCQ
- ឱសថសាស្ត្រគ្លីនីកនិងការអនុវត្តផ្នែកឱសថ — ៦០ សំណួរMCQ

គ. ថ្នាក់ទន្តបណ្ឌិត៖

- វិទ្យាសាស្ត្រមូលដ្ឋាន — ៤០ សំណួរMCQ
- ក្រមសីលធម៌ ឥរិយាបថ និងសុខភាពសាធារណៈ — ២០ សំណួរMCQ
- ការពិនិត្យជម្ងឺមាត់ធ្មេញ — ៤០ សំណួរMCQ

ឃ.ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាកៈ

- វិទ្យាសាស្ត្រមូលដ្ឋាន ៣០ សំណួរ MCQ
- វិទ្យាសាស្ត្រមូលដ្ឋានគ្រឹះ ១០ សំណួរ MCQ
- បែបបទថែទាំ ១០ សំណួរ MCQ
- ការថែទាំម្តាយ និងទារក ៥០ សំណួរ MCQ

❖ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥ ចាប់ពីម៉ោង ១៦:០០នាទីតទៅ

ក. ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖

- មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រ ២០ សំណួរ MCQ
- ជម្ងឺកុមារ ៤០ សំណួរ MCQ
- សម្ភព និងរោគស្ត្រី ៤០ សំណួរ MCQ

ខ.ថ្នាក់បរិញ្ញាបត្រឱសថ៖

- វិទ្យាសាស្ត្រឱសថ ១០០ សំណួរ MCQ

គ. ថ្នាក់ទន្តបណ្ឌិត៖

- ការព្យាបាលជម្ងឺមាត់ធ្មេញ ១០០ សំណួរMCQ

ឃ.ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាកៈ

- ការថែទាំមនុស្សពេញវ័យ និងការលើកកម្ពស់ទម្រង់ការថែទាំ ១០០ សំណួរ MCQ

២.២. ផ្នែកជំនាញគ្លីនីក៖

វិញ្ញាសាប្រឡងជំនាញគ្លីនីកប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ តទៅ ដែលមានស្ថានីយ៍ដូចខាងក្រោម៖

ក. ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖ មាន ៣ស្ថានីយ៍ ៖

- ❖ ស្ថានីយ៍ទី១៖ការសាកសួរប្រវត្តិជំងឺ(HistoryTaking)និង ការពិនិត្យរាងកាយ (Physical Examination)
- ❖ ស្ថានីយ៍ទី២៖ ការអង្កេតវិភាគ (Investigations) និងការធ្វើរោគវិនិច្ឆ័យ (Diagnostic Making)
- ❖ ស្ថានីយ៍ទី៣៖ គម្រោងព្យាបាល (Treatment Planning) និងការអប់រំសុខភាព (Patient Education)

ខ.ថ្នាក់បរិញ្ញាបត្រឱសថ៖ មាន ៥ស្ថានីយ៍ ៖

- ❖ ស្ថានីយ៍ទី១៖ ការប្រាស្រ័យទាក់ទងនិងផ្តល់ប្រឹក្សាដល់អ្នកជម្ងឺ(Counseling and Communication)
- ❖ ស្ថានីយ៍ទី២៖ ការពិនិត្យឱសថដែលមានវេជ្ជបញ្ជា(Review of Prescribed Medicines)
- ❖ ស្ថានីយ៍ទី៣៖ ការពិគ្រោះជម្ងឺ (Patient Consultation)
- ❖ ស្ថានីយ៍ទី៤៖ ការកំណត់រក និងការដោះស្រាយបញ្ហាដែលទាក់ទងនឹងឱសថ (Identification and Resolution of Drug-Related Problems)
- ❖ ស្ថានីយ៍ទី៥៖ការវាយតម្លៃលើឯកសារ/ការផ្តល់ព័ត៌មានអំពីឱសថ (Literature Evaluation and Drug Information)

គ. ថ្នាក់ទន្តបណ្ឌិត៖ មាន ៦ស្ថានីយ៍ ៖

- ❖ ស្ថានីយ៍ទី ១៖ ការសាកសួរប្រវត្តិជម្ងឺ ពិនិត្យជម្ងឺ អង្កេតវិភាគ និងធ្វើរោគវិនិច្ឆ័យ (History, Examination, Investigation & Diagnosis)
- ❖ ស្ថានីយ៍ទី ២៖ ការបកស្រាយរូបភាពវិទ្យុសាស្ត្រ (Interpretation of Radiographs)
- ❖ ស្ថានីយ៍ទី ៣៖ គំរោងព្យាបាលជម្ងឺ (Treatment Plan)
- ❖ ស្ថានីយ៍ទី ៤៖ ការដេរ និងចាក់ (Suturing & Injection)

- ស្ថានីយ៍ទី ៥៖ ការប្រាស្រ័យទាក់ទង (Communication)
- ស្ថានីយ៍ទី ៦៖ ការត្រួតពិនិត្យការបង្ករោគ (Cross Infection Control)

ឃ. ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក៖ មាន ៧ស្ថានីយ៍ ៖

- ស្ថានីយ៍ទី១ :ការលាងដៃដើម្បីអនុវត្តទម្រង់ការស្តេរីល (Washing Hands for Applying Sterilized Procedures)
- ស្ថានីយ៍ទី២:ការថែទាំផ្នែកសល្យសាស្ត្រ (Surgical Care)
- ស្ថានីយ៍ទី៣: ការថែទាំផ្នែកវេជ្ជសាស្ត្រ (Medical Care)
- ស្ថានីយ៍ទី៤: ការចាក់បញ្ចូលសារធាតុរាវឈាមនិងឱសថ (Catheterization)
- ស្ថានីយ៍ទី៥: ការត្រួតពិនិត្យការចំឡងរោគ (Infection Control)
- ស្ថានីយ៍ទី៦: ការសង្គ្រោះបន្ទាន់ (Cardio Pulmonary Resuscitation - CPR)
- ស្ថានីយ៍ទី៧: ការអប់រំអ្នកជម្ងឺ (Patient Health Education)

## ២.៣. ទីកន្លែងប្រឡងទ្រឹស្តី និងប្រឡងជំនាញគ្លីនីក

### *២.៣.១. ទីកន្លែងប្រឡងទ្រឹស្តី*

ការប្រឡងទ្រឹស្តី នឹងប្រព្រឹត្តទៅនៅសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។

### *២.៣.២. ទីកន្លែងប្រឡងជំនាញគ្លីនីក*

- ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖
  - នៅសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
  - នៅសាកលវិទ្យាល័យអន្តរជាតិ សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យអន្តរជាតិ
- ថ្នាក់បរិញ្ញាបត្រឱសថ៖
  - នៅសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
  - នៅសាកលវិទ្យាល័យអន្តរជាតិ សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យអន្តរជាតិ
- ថ្នាក់ទន្តបណ្ឌិត៖
  - នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
  - នៅសាកលវិទ្យាល័យអន្តរជាតិ សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យអន្តរជាតិ
- ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក៖
  - នៅសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សម្រាប់បេក្ខជនមកពីសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សាកលវិទ្យាល័យឡាយហ្វ និងសាកលវិទ្យាល័យចេនឡា
  - នៅសាកលវិទ្យាល័យអន្តរជាតិ សម្រាប់បេក្ខជនមកពីសាកលវិទ្យាល័យអន្តរជាតិ។

## ៣.សំណុំលិខិតដែលត្រូវបំពេញ

៣.១. ចំពោះនិស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិឆ្នាំ២០១៥ និងឆ្នាំកន្លងមកៈ

- បង្កាន់ដៃទទួលពាក្យ........................................................................................១ច្បាប់
- ពាក្យសុំចុះឈ្មោះប្រឡង...................................................................................២ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មី (៤ x ៦)...........................................................២ច្បាប់
- រូបថត ៤ x ៦ (ពណ៌ ថ្មី)....................................................................................៣សន្លឹក
- បញ្ជីលទ្ធផលប្រឡងចេញថ្នាក់ជាតិទាំងផ្នែកទ្រឹស្តី ទាំងផ្នែកជំនាញគ្លីនិក ក្នុងឆ្នាំ២០១៥ និងឆ្នាំកន្លងមក (បញ្ជីលទ្ធផលផ្តល់ដោយសាកលវិទ្យាល័យសាមី)

៣.២.ចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមិនទាន់បានប្រឡងចេញថ្នាក់ជាតិ បេក្ខជនត្រូវមានៈ

- បង្កាន់ដៃទទួលពាក្យ........................................................................................១ច្បាប់
- ពាក្យសុំចុះឈ្មោះប្រឡង...................................................................................២ច្បាប់
- ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មី (៤ x ៦)...........................................................២ច្បាប់
- រូបថត ៤ x ៦ (ពណ៌ ថ្មី)....................................................................................៣សន្លឹក
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ ព្រឹត្តប័ត្រពិន្ទុនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចេញដោយនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា ឬ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ-ខេត្ត ឬ សញ្ញាបត្រដែលមានតម្លៃស្មើ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ឬ គណៈកម្មាធិការវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សាច្បាប់ដើម ឬ ថតចម្លង ដោយមានបញ្ជាក់ពីសាលារាជធានីភ្នំពេញ-ខេត្ត (ភ្ជាប់មកជាមួយនូវច្បាប់ដើមដើម្បីផ្ទៀងផ្ទាត់)...........................................................២ច្បាប់
- វិញ្ញាបនបត្របញ្ចប់ការសិក្សា ចេញដោយគ្រឹះស្ថានបណ្តុះបណ្តាល...............................១ច្បាប់
- ព្រឹត្តប័ត្រពិន្ទុនៃការសិក្សាគ្រប់មុខវិជ្ជា និងគ្រប់ឆ្នាំសិក្សាចេញដោយគ្រឹះស្ថានបណ្តុះបណ្តាល... ..........................................................................................................................១ច្បាប់
- លទ្ធផលប្រឡងចូលរៀនថ្នាក់ជាតិក្នុងវិស័យសុខាភិបាល ឬ លទ្ធផលប្រឡង ឬ ជ្រើសរើសចូលរៀនដែលមានហត្ថលេខាទទួលស្គាល់ដោយក្រសួងសុខាភិបាល និង/ឬ ក្រសួងអប់រំ យុវជន និងកីឡា

## ៤. ទីកន្លែងដាក់ពាក្យ

ចាប់ទទួលពាក្យពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង ៥ល្ងាច នៅតាមសាកលវិទ្យាល័យ ដូចខាងក្រោមៈ

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលសម្រាប់និស្សិតដែលមកពីសាកលវិទ្យាល័យវិទ្យា-សាស្ត្រសុខាភិបាល
- សាកលវិទ្យាល័យអន្តរជាតិសម្រាប់និស្សិតដែលមកពីសាកលវិទ្យាល័យអន្តរជាតិ
- សាកលវិទ្យាល័យឡាយហ្វសម្រាប់និស្សិតដែលមកពីសាកលវិទ្យាល័យឡាយហ្វ
- សាកលវិទ្យាល័យចេនឡាសម្រាប់និស្សិតដែលមកពីសាកលវិទ្យាល័យចេនឡា។

<u>សម្គាល់</u>៖ សំណុំលិខិតពាក្យសុំប្រឡងចេញថ្នាក់ជាតិនិងព័ត៌មានផ្សេងៗទៀតសូមទាក់ទងនៅសាកលវិទ្យាល័យពាក់ព័ន្ធ។

## ៥. ការបង់សិទ្ធិប្រឡងៈ

**៥.១.ចំពោះនិស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិមុនឆ្នាំ២០១៥ៈ**

បេក្ខជនត្រូវៈ

- បង់ថ្លៃសិទ្ធិប្រឡងចំនួន ២៥ ដុល្លាអាមេរិក ក្នុង១នាក់ សម្រាប់ផ្នែកទ្រឹស្តី និង/ឬ
- បង់ថ្លៃសិទ្ធិប្រឡងចំនួន ១០០ ដុល្លាអាមេរិក ក្នុង១នាក់ សម្រាប់ផ្នែកជំនាញគ្លីនិក

**៥.២.ចំពោះនិស្សិតដែលបានប្រឡងធ្លាក់ក្នុងការប្រឡងចេញថ្នាក់ជាតិក្នុងឆ្នាំ២០១៥ៈ**

ចំពោះបេក្ខជនដែលបានបញ្ចប់ការសិក្សាមុនឆ្នាំ២០១៥ ហើយទើបបានចូលរួមប្រឡងចេញថ្នាក់ជាតិនាសម័យប្រឡងថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០១៥ បេក្ខជនត្រូវៈ

- បង់ថ្លៃសិទ្ធិប្រឡងចំនួន ២៥ ដុល្លាអាមេរិក ក្នុង១នាក់ សម្រាប់ការប្រឡងឡើងវិញផ្នែកទ្រឹស្តី ឬ
- បង់ថ្លៃសិទ្ធិប្រឡងចំនួន១០០ដុល្លាអាមេរិកក្នុង១នាក់ សម្រាប់ការប្រឡងឡើងវិញផ្នែកជំនាញគ្លីនិក

**៥.៣.ចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលដែលមិនទាន់បានប្រឡងចេញថ្នាក់ជាតិៈ**

បេក្ខជនដែលមានបំណងដាក់ពាក្យសុំប្រឡងចេញថ្នាក់ជាតិទាំងផ្នែកទ្រឹស្តី និងផ្នែកជំនាញគ្លីនិក ត្រូវបង់ថ្លៃសិទ្ធិប្រឡងចំនួន១២៥ដុល្លាអាមេរិក ក្នុង១នាក់ នៅតាមសាកលវិទ្យាល័យពាក់ព័ន្ធ។

<u>បញ្ជាក់</u>ៈ

- គណៈកម្មាធិការប្រឡងថ្នាក់ជាតិ នឹងប្រគល់ថវិកាសម្រាប់ការប្រឡងជំនាញគ្លីនិកចំនួន ១០០ ដុល្លាអាមេរិកជូនបេក្ខជនវិញ ក្នុងករណីដែលបេក្ខជនប្រឡងធ្លាក់ផ្នែកទ្រឹស្តីចំនួនពីរ(០២)ដងក្នុងឆ្នាំតែមួយតាមរយៈគ្រឹះស្ថានពាក់ព័ន្ធ
- ចំពោះបេក្ខជនអវត្តមានដែលបានទទួលច្បាប់អនុញ្ញាតពីគណៈកម្មាធិការប្រឡងថ្នាក់ជាតិកន្លងមក ត្រូវមកដាក់ពាក្យសុំចូលរួមប្រឡងចេញថ្នាក់ជាតិឡើងវិញ
- ករណីបេក្ខជនអវត្តមានមិនបានចូលរួមការប្រឡងតាមការគ្រោងទុក ត្រូវចាត់ទុកថាធ្លាក់ដោយស្វ័យប្រវត្តិ និងមិនប្រគល់ថវិកាបង់សិទ្ធិប្រឡងជូនវិញទេ
- ក្នុងករណីរកឃើញថា បេក្ខជន/បេក្ខនារី ក្លែងបន្លំសញ្ញាបត្រ ឬឯកសារពាក់ព័ន្ធ ត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតនៅតាមសាកលវិទ្យាល័យដែលខ្លួនកំពុងរៀនបច្ចុប្បន្ន និងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន
- ចំពោះករណីរកឃើញថាមានការប្រឡងជំនួស អ្នកប្រឡងជំនួសគេ ត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតដែលខ្លួនកំពុងរៀនបច្ចុប្បន្ន នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន
- ចំពោះ បេក្ខជន/បេក្ខនារី ដែលឱ្យគេប្រឡងជួស ត្រូវចាត់ទុកថាធ្លាក់ដោយស្វ័យប្រវត្តិ
- នៅថ្ងៃប្រឡងបេក្ខជន/បេក្ខនារីត្រូវយកជាប់ជាមួយខ្លួននូវបង្កាន់ដៃទទួលពាក្យនិងប័ណ្ណសម្គាល់ខ្លួន។ ក្នុងករណី បេក្ខជន/បេក្ខនារីមិនមានបង្កាន់ដៃទទួលពាក្យ និងប័ណ្ណសម្គាល់ខ្លួន នឹងមិនអនុញ្ញាតឱ្យចូលក្នុងបន្ទប់ប្រឡងឡើយ។

**ជ.គណៈកម្មាធិការប្រឡងថ្នាក់ជាតិ**
**សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល**
**ប្រធាន**

**សេង លឹមនៅ**

ចម្លងជូនៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសុខាភិបាល
-ក្រសួងអប់រំ យុវជន និងកីឡា
-សាកលវិទ្យាល័យពាក់ព័ន្ធ
-កាលប្បវត្តិ
-ឯកសារ លេខាធិការដ្ឋាន គ.ប.ជ